ក្នុងឱកាសបុណ្យចូលឆ្នាំខ្មែរដែលជាប្រពៃណីជាតិនេះ,យើងខ្ញុំជាសមាជិក-សមាជិការបស់សាខាគណបក្សសិទ្ធិមនុស្សប្រចាំរដ្ឋផែនស៊ីវៀនៀ សូមប្រសិទ្ធពរដល់ពលរដ្ឋខ្មែរគ្រប់ច្រកល្ហក, គ្រប់ស្រទាប់វណ្ណៈ និងគ្រប់គណបក្សនយោបាយទាំងអស់ ឱ្យជួបតែសេរីសួស្តី វិបុលសុខគ្រប់ទិនទិវារាត្រី ។

គណកម្មការគណបក្សសិទ្ធិមនុស្ស ប្រចាំរដ្ឋផែនស៊ីវៀនៀ

មានជំនាញខាងទិញ.លក់ផ្ទះ.ពាណិជ្ជកម្ម. វិនិយោគ ហិរញ្ញវត្ថុ ឬជួល
ជើងសាតំណាងរបស់លោកអ្នកដែលធ្វើវិនិយោគ

Vinh Ho, 215-391-9516

Email: vho.realestate@consultant.com

ANCHOR Real Estate Development
320 Oregon Ave, #3B, Philadelphia, PA 19148

Specialize - Buy_Sell_Invest_Finance_Rent ...
Beginner-investors are welcomed!

HOME FOR SALE

តំបន់ល្អជិតផ្សារ TWIN មាន Garage,
3Bedroom, 2 Baths តម្លៃថោកល្អ
នៅ NE. **$129,999**
5433 West Ford Rd. Northeast
Phila., PA 19120 សូមទាក់ទង
Mr.Vandy (215) 329-5183 or (267) 253-5845

FOR SALE BY OWNER

HASS´S AUTO ជួសជុលតួឡានដែលបុកគ្នាម្ចាស់ហាងចូលនិវត្តន៍-ហាងមានដំណើរការ១៧ឆ្នាំមកហើយ -ពាណិជ្ជកម្មមានល់នឹងល្អគ្រប់រដូវលោកអ្នកអាចទិញតែពាណិជ្ជកម្មក៏បាន-ទិញដីជាមួយនឹងផ្ទះក៏បាន -ទិញទាំងពីររួមគ្នាក៏បាន បើចង់ដឹងច្បាស់សូមទូរស័ព្ទរកឈ្មោះ "នីក"

Owner is retiring. 17 years in business at this location. Well established business, all seasons are busy. Option to buy only business, real estate, or both.

BODY SHOP ENTRANCE

Contact Nick: 267-242-7938
615 W. Fisher Ave. Phila, Pa 191203

NOEL TAX CONSUL TANTS

LICENSED & INSURED

Financial Services

សេវាប្រកបដោយវិជ្ជាជីវៈ :

- ខ្ចីប្រាក់ទិញផ្ទះ MORTGAGE
- អន្តោប្រវេសន៍ IMMIGRATION
- បកប្រែភាសា TRANSLATION
- ធ្វើប្រថាប់ត្រាបញ្ជាក់លិខិតផ្លូវការ-NOTARY
- មានសេវាមើលកូន នឹងថែទាំផ្ទះសម្បែង

ណូអែល មជ្ឈមណ្ឌលសេវាធ្វើតាក់

សម្រាប់មុខរបរ ឬឯកជន-កត់ត្រាចំណូលចំណាយប្រចាំថ្ងៃនឹងប្រចាំត្រីមាស
អ្នកឯកទេសចំណាន នឹងធ្វើតាក់យ៉ាងប្រសើរជូនលោកអ្នក

អាសយដ្ឋាន : 6341RISING SUN AVE
Philadelphia PA 1911

Phone : (215) 821-2443
Fax : (215) 821-2446
E-mail : noel.tax@gmail.com

Sav-Mor PHARMACY Tel: 215-467-1220

ឱសថស្ថានខ្មែរ

Sav-Mor PHARMACY
Sam EA R.Ph.
2232 S. 7th St. (7th & Wolf) Philadelphia, Pa 19148
Tel: 215.467.1220 Fax: 215.467.1447

បំរើលោកអ្នកដោយមិត្តភាព និងទាន់ចិត្ត

▸▸Sav-Mor គឺជាឱសថស្ថានបំរើ ការចែកចាយថ្នាំ ហើយអាចពន្យល់ពីរបៀបប្រើប្រាស់ថ្នាំ តាមវេជ្ជបញ្ជាជាភាសាខ្មែរបាន

▸▸យើងទទួលយកនូវ MEDICARE MEDICAID និង INSURANCES ជាច្រើនទៀតផង យើងមានលក់កាត សំរាប់ទូរស័ព្ទទៅស្រុកខ្មែរ ឬទៅអន្តរជាតិ

*Accept most insurance plans including Medicare & Medicaid
*Easy Prescription transfer
*Inside. Prepaid phone card. Call Cambodia.

ឌី ឃែមបូឌា ដេលី The Cambodia Daily

Oz Minerals Releases Exploration Results

By Simon Marks
THE CAMBODIA DAILY

Oz Minerals released exploration results yesterday that announced having found an initial resource of 605,000 ounces of gold at its operational site in Okvau Ochung in Mondolkiri province, where the company has identified four separate mining targets. The findings estimate the area contains 2.3 grams of gold per ton of earth.

The find was recovered from more than 10,000 meters worth of drill holes—made since 2006—over an area stretching 400 meters by 500 meters. Drill holes went as deep as 400 meters.

"We are very pleased with the initial resource," Terry Burgess, CEO of Oz Minerals, wrote in an e-mail yesterday.

"Okvau is the first area we have tested in detail and there are a number of similar looking targets to explore. This project is still in its early stages and we believe there is potential for this area to be a gold district," he said.

In a separate statement the company said future exploration operations would now concentrate on further drill targets within a 3-km radius of Okvau that are believed to have similar mineral content.

Oz Minerals has located four other locations around the province for exploration to be conducted, though Okvau is said to be the company's main project area.

Yesterday's results mark a sizable decrease from results released in October, which at one drill hole showed 5.93 grams of gold per ton of earth over a 5-meter interval 25 meters deep near the O Te River.

Oz Minerals' operations in Cambodia are still in their early stages and it is still too early to speculate about a potential time frame for full-scale mining, the company said.

Still, the "size of the initial Okvau resource has provided Oz Minerals sufficient encouragement to continue exploration in the Okvau district," the company said in a statement, adding the next phase of exploration will give a clear indication as to whether or not previous targets of extracting two million ounces of gold in the area is reachable.

Oz Minerals is listed on the Australian Securities Exchange. Shares at the company closed down 1.71 percent yesterday at A$1.15.

ក្រុមហ៊ុន Oz Minerals ប្រកាសថា ខ្លួនបានរកឃើញរ៉ែមាស

THE CAMBODIA DAILY

ក្រុមហ៊ុន Oz Minerals កាលពីម្សិលមិញបានចេញលទ្ធផលរុករករ៉ែដែលរកឃើញធនធានដំបូងនៃរ៉ែមាសចំនួន៦០៥.០០០អោនស៍ក្នុងទីតាំងប្រតិបត្តិការរបស់ខ្លួននៅក្នុងស្រុកអូរខ្វាវ អូរជុំ ក្នុងខេត្តមណ្ឌលគិរី ជាទីដែលក្រុមហ៊ុននេះបានរកឃើញគោលដៅរុករករ៉ែចំនួន៤កន្លែងដោយឡែកពីគ្នា។ ការរកឃើញនេះធ្វើឲ្យមានការប៉ាន់ប្រមាណថា តំបន់នោះមានរ៉ែមាស២,៣ក្រាមក្នុងដី១តោន។

លទ្ធផលនេះត្រូវបានរកឃើញពីរន្ធខួងដែលមានជម្រៅ ១០.០០០ម៉ែត្រ(ដែលជីកចាប់តាំងពីឆ្នាំ២០០៦)នៅក្នុងតំបន់មួយដែលមានទំហំលាតសន្ធឹង៤០០ម៉ែត្រគុណនឹង៥០០ម៉ែត្រ។ រន្ធខួងទាំងនេះមានជម្រៅ៤០០ម៉ែត្រ។

លោក Terry Burgess នាយកប្រតិបត្តិក្រុមហ៊ុន Oz Minerals បានសរសេរនៅក្នុងអ៊ីម៉ែលកាលពីម្សិលមិញថា "យើងរីករាយណាស់ចំពោះធនធានដំបូងនេះ"។

លោកបាននិយាយថា "អូរខ្វាវគឺជាតំបន់ទី១ដែលយើងបានធ្វើតេស្តលំអិត ហើយមានគោលដៅស្រដៀងគ្នានេះផ្សេងៗទៀតដើម្បីធ្វើការរុករករ៉ែ។ គម្រោងនេះនៅតែស្ថិតក្នុងដំណាក់កាលដំបូងនៅឡើយ ហើយយើងជឿជាក់ថា មានសក្តានុពលសម្រាប់តំបន់នេះក្នុងការក្លាយជាស្រុកដែលពោរពេញទៅដោយមាស។

នៅក្នុងសេចក្តីថ្លែងការណ៍ដោយឡែកមួយ ក្រុមហ៊ុននេះបានឲ្យដឹងថា ប្រតិបត្តិការរុករករ៉ែនាថ្ងៃអនាគតឥឡូវនេះនឹងលើបណ្តាគោលដៅជីកបន្ថែមទៀតក្នុងរង្វង់៣គីឡូម៉ែត្រពីអូរខ្វាវ ដែលគេជឿជាក់ថា មានពពួករ៉ែស្រដៀងគ្នានេះ។

Oz Minerals បានរកឃើញទីតាំង៤កន្លែងទៀតនៅជុំវិញខេត្តនេះសម្រាប់ការធ្វើប្រតិបត្តិការរុករករ៉ែ ថ្វីបើអូរខ្វាវត្រូវបានចាត់ទុកថា ជាតំបន់ចម្បងសម្រាប់គម្រោងរបស់ក្រុមហ៊ុននេះក៏ដោយ។

លទ្ធផលកាលពីម្សិលមិញស្តែងឲ្យឃើញពីការធ្លាក់ចុះគួរសមពីលទ្ធផលមុនៗដែលត្រូវបានចេញផ្សាយនៅក្នុងខែតុលា ដែលក្នុងរណ្តៅជីកមួយមានរ៉ែមាសចំនួន៥,៩៣ក្រាមក្នុងដី១តោននៃរណ្តៅមានជម្រៅចន្លោះពី៥ម៉ែត្រទៅ២៥ម៉ែត្រនៅក្បែរស្ទឹងអូរតេ។

ក្រុមហ៊ុននេះបាននិយាយថា ប្រតិបត្តិការរុករករ៉ែរបស់ក្រុមហ៊ុន Oz Minerals គឺស្ថិតនៅក្នុងដំណាក់ដំបូងរបស់ពួកគេនៅឡើយ ហើយវានៅឆាប់រហ័សពេកមិនអាចប៉ាន់ស្មានអំពីពេលវេលាដែលមានសក្តានុពលសម្រាប់ការរុករករ៉ែក្នុងទ្រង់ទ្រាយពេញលេញបានទេ។

ទោះជាយ៉ាងណាក៏ដោយ ក្រុមហ៊ុននេះបានសរសេរនៅក្នុងសេចក្តីថ្លែងការណ៍មួយថា "ទំហំនៃធនធានដំបូងនៅអូរខ្វាវនោះបានផ្តល់ការជំរុញទឹកចិត្តគ្រប់គ្រាន់ដល់ក្រុមហ៊ុន Oz Minerals ដើម្បីបន្តរុករករ៉ែនៅស្រុកអូរខ្វាវនេះ"។ ក្រុមហ៊ុននេះបានសរសេរបន្ថែមថា ដំណាក់បន្ទាប់នៃការរុករករ៉ែនឹងផ្តល់ការបង្ហាញឲ្យឃើញច្បាស់លាស់ថា តើគោលដៅមុនៗនៃការទាញយករ៉ែមាសចំនួន២លានអោនស៍នៅក្នុងតំបន់នោះគឺអាចធ្វើទៅបានឬយ៉ាងណានោះ។

ក្រុមហ៊ុន Oz Minerals ត្រូវបានចុះបញ្ជីនៅលើទីផ្សារមូលប័ត្ររបស់អូស្ត្រាលី។ ភាគហ៊ុននៅក្រុមហ៊ុននេះបានបិទក្នុងចំនួន១,៧១ភាគរយកាលពីថ្ងៃព្រហស្បតិ៍ក្នុងតម្លៃ១,១៥ដុល្លារអូស្ត្រាលី ។P

Gov't Spending Ineffective in '09, Report Says

By Simon Marks
THE CAMBODIA DAILY

Government spending during the course of last year's economic crisis was ineffective and, coupled with the effects of the global recession, added to increased poverty levels in Cambodia, a new report released on Wednesday by the Cambodia Development Resource Institute says.

Released at the annual economic outlook conference in Phnom Penh on Wednesday, the report, titled "Annual Development Review 2009-10," also said there has so far been little thought put into actual government policy responses to exit from the economic crisis. "[A] large share of additional spending went to the military and civil service wages at the expense of priority sectors," the report states.

For 2010, the total military and defense budget amounts to $276 million while that for agriculture only reaches $20 million. The report goes on to state that while the global economic crisis put strain on certain sectors within the economy, it also uncovered deeper systemic issues.

"Perhaps in the haste to have a taste of development, the take-off of its [Cambodia's] economy has been initiated without...undertaking the necessary preparations," the report states.

The message from John Nelmes, resident representative for the International Monetary Fund, on Wednesday, provided similar thoughts on the subject of macroeconomic planning. Economic growth is a bonus "as long as it's in the context of macroeconomic stability," Mr Nelmes said. He said a greater focus on spending measures in the health and education sectors would be essential as Cambodia, hopefully, moves toward positive growth.

Finance Ministry Secretary-General Hang Chuon Naron, who spoke at Wednesday's conference, said yesterday that the government will reform sectoral spending patterns to ensure priority areas within the economy such as health and education are adequately covered. Mr Chuon Naron, however, did not provide details or a timetable for reforms.

"There are lots of things in terms of concrete projects," he said, adding the development of a social safety net program as well as better health care and infrastructure in rural areas were on the government's agenda.

របាយការណ៍: ការចំណាយរបស់រដ្ឋាភិបាលក្នុងឆ្នាំ២០០៩គ្មានប្រសិទ្ធភាព

ដោយ Simon Marks
THE CAMBODIA DAILY

របាយការណ៍ថ្មីមួយដែលចេញផ្សាយកាលពីថ្ងៃពុធ ដោយវិទ្យាស្ថានអភិវឌ្ឍន៍ធនធានកម្ពុជាបានឲ្យដឹងថា ការចំណាយរបស់រដ្ឋាភិបាលអំឡុងរយៈពេលនៃវិបត្តិសេដ្ឋកិច្ចកាលពីឆ្នាំមុនមិនមានប្រសិទ្ធភាពទេ ហើយផលប៉ះពាល់ដោយសារវិបត្តិសេដ្ឋកិច្ចពិភពលោកនេះបានបន្ថែមទៅលើកម្រិតភាពក្រីក្រដែលបានកើនឡើងនៅក្នុងប្រទេសកម្ពុជា។

ដោយចេញផ្សាយនៅឯសន្និសីទស្តីពីទស្សនវិស័យសេដ្ឋកិច្ចប្រចាំឆ្នាំនៅក្នុងទីក្រុងភ្នំពេញកាលពីថ្ងៃពុធ របាយការណ៍ដែលមានចំណងជើងថា "ការពិនិត្យមើលការអភិវឌ្ឍប្រចាំឆ្នាំ២០០៩និង២០១០" ក៏បានឲ្យដឹងផងដែរថារហូតមកដល់ពេលនេះមានការគិតគូរតិចតួចពីការឆ្លើយតបតាមគោលនយោបាយជាក់ស្តែងរបស់រដ្ឋាភិបាលទៅនឹងការចាកចេញពីវិបត្តិសេដ្ឋកិច្ច។

របាយការណ៍នេះក៏បានអះអាងផងដែរថា "ចំណែកដ៏ធំនៃការចំណាយបន្ថែមបានធ្លាក់ទៅលើវិស័យយោធានិងប្រាក់ខែមន្ត្រីរាជការក្រោមការខាតបង់របស់វិស័យជាអាទិភាពមួយចំនួន"។

សម្រាប់ឆ្នាំ២០១០នេះ ថវិកាសរុបសម្រាប់វិស័យយោធានិងការការពារឡើងដល់២៧៦លានដុល្លារ ចំណែកឯថវិកាសម្រាប់វិស័យកសិកម្មវិញមានត្រឹមតែ២០លានដុល្លារប៉ុណ្ណោះ។

របាយការណ៍នេះបន្តអះអាងថា ខណៈដែលវិបត្តិសេដ្ឋកិច្ចពិភពលោកបានបង្កការលំបាកទៅលើវិស័យសំខាន់ៗមួយចំនួននៅក្នុងសេដ្ឋកិច្ច វាក៏បានបង្ហាញឲ្យឃើញនូវបញ្ហាដែលមានលក្ខណៈជាប្រព័ន្ធនិងស៊ីជម្រៅជាងនេះផងដែរ។

របាយការណ៍នេះបានអះអាងថា "ប្រហែលដោយសារតែការប្រញាប់ប្រញាល់ចង់បានការអភិវឌ្ឍនោះ ដំណើរសេដ្ឋកិច្ចរបស់កម្ពុជាត្រូវបានផ្តួចផ្តើមឡើងដោយគ្មាន... ការត្រៀមខ្លួនដែលចាំបាច់"។

កាលពីថ្ងៃពុធ សារដែលផ្តល់ដោយលោក ចន ណែលមេស តំណាងប្រចាំប្រទេសរបស់មូលនិធិរូបិយវត្ថុអន្តរជាតិក៏បានផ្តល់យោបល់ស្រដៀងគ្នាស្តីពីកម្មវត្ថុនៃការរៀបចំផែនការម៉ាក្រូសេដ្ឋកិច្ចផងដែរ។

លោក ចន ណែលមេស បានមានប្រសាសន៍ថា កំណើនសេដ្ឋកិច្ចគឺជារង្វាន់លើកទឹកចិត្តមួយ "ដរាបណាវាស្ថិតនៅក្នុងបរិបទនៃស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច"។

លោក ចន ណែលមេស បានមានប្រសាសន៍បន្ថែមទៀតថា ការយកចិត្តទុកដាក់ខ្លាំងជាងនេះទៅលើវិធានការចំណាយទាំងនៅក្នុងវិស័យសុខាភិបាលនិងអប់រំនឹងមានសារៈសំខាន់ណាស់ ខណៈប្រទេសកម្ពុជាសង្ឃឹមថា នឹងបោះជំហានទៅរកកំណើនវិជ្ជមាន។

លោក ហង្ស ជួនណារ៉ុន អគ្គលេខាធិការក្រសួងហិរញ្ញវត្ថុ ដែលថ្លែងនៅក្នុងសន្និសីទកាលពីថ្ងៃពុធបានមានប្រសាសន៍កាលពីម្សិលមិញថា រដ្ឋាភិបាលនឹងកែទម្រង់គំរូចំណាយលើវិស័យផ្សេងៗដើម្បីធានាថា វិស័យជាអាទិភាពនៅក្នុងសេដ្ឋកិច្ចដូចជាវិស័យសុខាភិបាលនិងវិស័យអប់រំ ត្រូវបានបំពេញដោយសមស្រប។ ទោះជាយ៉ាងណា លោក ហង្ស ជួនណារ៉ុន មិនបានផ្តល់ពត៌មានលំអិតឬកាលវិភាគសម្រាប់ការកែទម្រង់បែបនេះទេ។

លោកបានមានប្រសាសន៍ថា "មានរឿងជាច្រើនពាក់ព័ន្ធទៅនឹងគម្រោងជាក់លាក់" ដោយលោកបានបន្ថែមថា ការអភិវឌ្ឍកម្មវិធីបណ្តាញសុវត្ថិភាពសង្គមព្រមទាំងការថែទាំសុខភាពនិងហេដ្ឋារចនាសម្ព័ន្ធប្រសើរជាងនេះនៅតាមជនបទគឺស្ថិតនៅក្នុងរបៀបវារៈរបស់រដ្ឋាភិបាល ។L

(តមកពីទំព័រទី ០៨)

ឧត្តមសេនីយត្រី...

អង្គារ ប៉ុន្តែទោសនេះត្រូវបានបន្ថយភ្លាមៗមកត្រឹម១០ថ្ងៃ ។ ទោះជាយ៉ាងណាឧត្តមសេនីយរូបនេះមិនបានមកតុលាការទេ ពីព្រោះគាត់បានទៅសម្រាក នៅមន្ទីរពេទ្យបានទៅហើយ។

លោក សុខ សោភា ប្រធានពន្ធនាគារខេត្តបាន និយាយកាលពីម្សិលមិញថា ការជាប់ពន្ធនាគាររបស់ឧត្តមសេនីយត្រី មុន្នីសូកា និងបញ្ចប់នៅថ្ងៃចន្ទ ។ ប្រធានពន្ធនាគាររូបនោះបានបន្តទៀតថា គាត់ក៏មានអ្នកយាមនៅក្នុងមន្ទីរពេទ្យផងដែរ។

លោក សោភា បាននិយាយថា "ខ្ញុំបានបញ្ជូនបុគ្គលិកពន្ធនាគារពីរនាក់ទៅយាមគាត់ ប៉ុន្តែយើងមិនបានដាក់ខ្នោះដៃគាត់ទេ ពីព្រោះខ្ញុំគិតថា គាត់ត្រូវបានដាក់ទោសសម្រាល"។

លោក ថាន ផានិត មេធាវីរបស់ឧត្តមសេនីយរូបនោះបាននិយាយកាលពីពេលកន្លងទៅថា លោកមិនអាចនិយាយជាមួយកូនក្តីរបស់លោកបានទេ ដោយសារតែជំងឺរបស់គាត់ ។ ទោះជាយ៉ាងណាលោក ចាន់ វិបុល ប្រធានមន្ទីរពេទ្យនោះបាននិយាយថា អ្នកជំងឺរូបនេះមិនឈឺធ្ងន់ទេ។

លោក ជាប សុធារី អ្នកសម្របសម្រួលប្រចាំខេត្តរបស់អង្គការសិទ្ធិមនុស្សនៅក្នុងស្រុក (អាដហុក) បាននិយាយថា ឧត្តមសេនីយរូបនេះហាក់បីដូចជាបានទទួលការយកចិត្តទុកដាក់ពិសេសហើយ ប្រសិនប្រជាពលរដ្ឋធម្មតាត្រូវបានរកឃើញកំហុសពីបទវាយតែបែបនេះ ពួកគេទំនងជាពន្ធនាគារ៦ខែទៅហើយ មិនមែនជាប់១០ថ្ងៃនៅលើគ្រែពេទ្យនោះទេ៕

United States® Census 2010

គោលការណ៍ណែនាំស្ដីអំពីជំនួយខាងផ្នែកភាសានៃការ ខ្មែរ / KHMER

U.S. DEPARTMENT OF COMMERCE
Economics and Statistics Administration
U.S. CENSUS BUREAU

- គោលការណ៍ណែនាំនេះផ្ដល់ជូននូវការបកប្រែសំណួរ សេចក្ដីណែនាំ នៃជំរឿន ព្រមទាំងផ្ដល់ជូននូវបែបផ្សេងៗនៃចម្លើយ ដែលមាននៅក្នុងតារាងសំណួរជំរឿនប្រចាំឆ្នាំ 2010 ចេញជាផ្លូវការសំរាប់លោកអ្នក ។
- [illegible] ... 2010 ចេញជាផ្លូវការសំរាប់លោកអ្នក ។
- សូមផ្ញើត្រឡប់មកវិញនូវតារាងសំណួរនៃជំរឿនប្រចាំឆ្នាំ 2010 ចេញជាផ្លូវការសំរាប់លោកអ្នកដែលត្រូវបានបំពេញចប់សព្វគ្រប់ ។ **សូមកុំ** ផ្ញើត្រឡប់ មកវិញនូវគោលការណ៍ណែនាំស្ដីពីជំនួយផ្នែកភាសានេះ ។

សូមចាប់ផ្ដើមនៅកន្លែងនេះ

សូមប្រើប៊ិចពណ៌ខ្មៅ ឬ ខៀវ ។

[illegible] 1 ខែ មេសា ឆ្នាំ 2010 ។

[illegible] (apartment) ឬ ផ្ទះចល័ត (mobile home) [illegible] ។

- [illegible]

[illegible]

- [illegible]
- [illegible] (nursing home) [illegible] 1 ខែ មេសា ឆ្នាំ 2010 [illegible] ។
- [illegible]

[illegible]

- នៅថ្ងៃទី 1 ខែ មេសា ឆ្នាំ 2010 [illegible] ។

1. នៅថ្ងៃទី 1 ខែ មេសា ឆ្នាំ 2010 [illegible] ?
   ចំនួនមនុស្ស = ☐

2. នៅថ្ងៃទី 1 ខែ មេសា ឆ្នាំ 2010 [illegible] 1 ដែរឬទេ ?
   សូមគូសសញ្ញា [X] [illegible] ។
   - ☐ [illegible]
   - ☐ [illegible]
   - ☐ [illegible]
   - ☐ [illegible]
   - ☐ [illegible]

3. [illegible] —
   សូមគូសសញ្ញា [X] ចម្លើយតែមួយ ។
   - ☐ [illegible]
   - ☐ [illegible]
   - ☐ [illegible] ?
   - ☐ [illegible] ?

4. [illegible] ?
   [illegible]
   ☐☐☐ - ☐☐☐ - ☐☐☐☐

Form D-60(Khmer) (11-24-2008)

USCENSUSBUREAU

5. សូមផ្ដល់ព័ត៌មានអំពីមនុស្សម្នាក់ៗដែលកំពុងរស់នៅទីនេះ ។
   [illegible] 1 ។

   តើមនុស្សទី 1 ឈ្មោះអ្វី ? [illegible] ។
   នាមត្រកូល ☐
   នាមខ្លួន ☐ អក្សរដំបូងនៃឈ្មោះកណ្ដាល ☐

6. តើមនុស្សទី 1 មានភេទអ្វី ? សូមគូសសញ្ញា [X] ចម្លើយតែមួយ ។
   - ☐ ភេទប្រុស
   - ☐ ភេទស្រី

7. តើមនុស្សទី 1 មានអាយុប៉ុន្មាន ហើយមានថ្ងៃ ខែ ឆ្នាំ កំណើតប៉ុន្មាន ?
   [illegible] 1 ឆ្នាំ [illegible] 0 ឆ្នាំ ។
   អាយុគិតនៅថ្ងៃទី 1 ខែ មេសា ឆ្នាំ 2010 ☐ ខែ ☐ ថ្ងៃ ☐ ឆ្នាំកំណើត ☐

→ កំណត់សម្គាល់ : [illegible] 8 [illegible] 9 [illegible] ។

8. តើមនុស្សទី 1 [illegible] ?
   - ☐ [illegible]
   - ☐ [illegible]
   - ☐ [illegible]
   - ☐ [illegible]
   - ☐ [illegible]

9. តើមនុស្សទី 1 មានពូជសាសន៍អ្វី ? សូមគូសសញ្ញា [X] [illegible] ។
   - ☐ [illegible]
   - ☐ [illegible]
   - ☐ [illegible]
   - ☐ [illegible]
   - ☐ [illegible]

10. [illegible] ?
    - ☐ ទេ
    - ☐ បាទ/ចាស — [illegible]

→ [illegible] 2 ។

សូមគូសចម្លើយរបស់លោកអ្នកនៅលើតារាងសំណួរសម្រាប់ជំរឿនប្រចាំឆ្នាំ 2010 [illegible] ។

1. សូមសរសេរឈ្មោះរបស់មនុស្សទី 2 ដល់ទី 6
   នាមត្រកូល ☐
   នាមខ្លួន ☐ ☐
   អក្សរដំបូងនៃឈ្មោះកណ្ដាល

2. តើមនុស្សនេះមានទំនាក់ទំនងយ៉ាងដូចម្ដេចជាមួយនឹងមនុស្សទី 1? សូមគូសសញ្ញា [X] ចម្លើយតែមួយ ។
   - ☐ ប្ដី ឬ ប្រពន្ធ
   - ☐ កូនប្រុស ឬ កូនស្រីបង្កើត
   - ☐ កូនប្រុស ឬ កូនស្រីចិញ្ចឹម
   - ☐ [illegible]
   - ☐ [illegible]
   - ☐ [illegible]
   - ☐ [illegible]
   - ☐ ឪពុក ឬ ម្ដាយក្មេក
   - ☐ កូនប្រសារប្រុស ឬ កូនប្រសារស្រី
   - ☐ សាច់ញាតិដទៃទៀត
   - ☐ [illegible]
   - ☐ [illegible]
   - ☐ [illegible]
   - ☐ [illegible]

3. តើមនុស្សនេះមានភេទអ្វី ? [illegible] ។
   - ☐ ភេទប្រុស
   - ☐ ភេទស្រី

4. តើមនុស្សនេះមានអាយុប៉ុន្មាន ហើយ មានថ្ងៃខែឆ្នាំកំណើតប៉ុន្មានដែរ ?
   [illegible]
   អាយុគិតនៅថ្ងៃទី 1 ខែ មេសា ឆ្នាំ 2010 ☐ ខែ ☐ ថ្ងៃ ☐ ឆ្នាំកំណើត ☐

→ កំណត់សម្គាល់ : [illegible] 5 [illegible] 6 [illegible] ។

5. [illegible] ?
   - ☐ ទេ [illegible]
   - ☐ [illegible]
   - ☐ [illegible]
   - ☐ [illegible]
   - ☐ [illegible]

6. តើមនុស្សនេះមានពូជសាសន៍អ្វី? [illegible]
   - ☐ [illegible]
   - ☐ [illegible]
   - ☐ [illegible]
   - ☐ សាសន៍ដទៃទៀត — [illegible]

7. [illegible] ?
   - ☐ ទេ
   - ☐ បាទ/ចាស — [illegible]

→ [illegible] 3 ។

Page 2

ប្រសិនបើលោកអ្នកមិនមានចន្លោះដើម្បីរាយមនុស្សរាល់គ្នាដែលរស់នៅក្នុងផ្ទះ ឬអាផាតមិន សូមរាយព័ត៌មានផ្សេងទៀតនៅខាងក្រោម ។
[illegible]

មនុស្សទី 7 ដល់ទី 12

នាមត្រកូល ☐
នាមខ្លួន ☐ អក្សរដំបូងនៃឈ្មោះកណ្ដាល ☐
ភេទ ☐ ប្រុស ☐ ស្រី
អាយុគិតនៅថ្ងៃទី 1 ខែ មេសា ឆ្នាំ 2010 ☐
ថ្ងៃខែឆ្នាំកំណើត ខែ ☐ ថ្ងៃ ☐ ឆ្នាំ ☐
[illegible] 1 ដែរឬទេ ? ☐ បាទ/ចាស ☐ [illegible]

ដើម្បីទទួលព័ត៌មានបន្ថែមអំពីជំរឿនប្រចាំឆ្នាំ 2010 នេះ សូមចូលទៅគេហទំព័រខាងក្រោម :
<http://www.census.gov/2010census>.

សូមចងចាំ :
សូមផ្ញើត្រឡប់មកវិញនូវតារាងសំណួរសម្រាប់ជំរឿនប្រចាំឆ្នាំ 2010 ជាផ្លូវការណ៍ របស់លោកអ្នកដែលត្រូវបានបំពេញចប់សព្វគ្រប់ ។ សូមកុំផ្ញើត្រឡប់មកវិញនូវគោលការណ៍ណែនាំស្ដីពីជំនួយផ្នែកភាសានេះ ។

សូមអរគុណ ។



ពីរដ្ឋបាលកុលសម្ព័ន្ធមករដ្ឋាភិបាលសម័យ

ប្រែសម្រួលដោយ : ពិន សំខុន (តពីលេខមុន)

-ខែមករា : ទស្សនកិច្ចសម្តេចសីហនុ អ្នកម្នាង មូនិក និង ខៀវ សំផន នៅខេត្តកំពង់ចាម ។

-ខែកុម្ភៈ : ខៀវ សំផន, ប៉ែន នុត, សម្តេចសីហនុ និងអ្នកម្នាងមូនិក ទៅធ្វើទស្សនកិច្ចនៅខេត្តបាត់ដំបង, ស៊ីសុផុន (អ្នកទាំងអស់បានទទួលបដិសណ្ឋារកិច្ច លោករដ្ឋមន្ត្រីថៃ ឆាតឆៃ ឆូណាវ៉ាន់ ដែលនឹងក្លាយទៅជារដ្ឋមន្ត្រីថៃ ពីឆ្នាំ១៩៨៨-១៩៩១) ទៅសៀមរាប, អង្គរ, កំពង់ធំ, នៅពេលកំពុងទស្សនាសៀមរាប បានត្រូវគេយល់ថា គឺជារដ្ឋប្រហារ ។

ថ្ងៃ៦កុម្ភៈ : ការចុះហត្ថលេខាយោធាសំងាត់រវាងចិន និងខ្មែរ KD ។

-ថ្ងៃ១៧-១៨កុម្ភៈ : ហ្វ្រង់ស្វា ប៉ុងសុន សរសេរនៅក្នុងកាសែត (ឡឺម៉ុង) ប្រទេសបារាំង បញ្ជាក់ជាថ្មីម្តងទៀតពីស្ថានភាពនរកក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

-២០មីនា : បោះឆ្នោតជ្រើសរើស "សភាតំណាងប្រជាជនកម្ពុជា" ចំនួន២៥០នាក់ ដែលមាន១៥០នាក់មកពីកសិករ, ៥០នាក់ មកពីកម្មករ និង៥០ទៀតមកពីយោធា សាឡុតស បានជាប់ជាតំណែងកម្មករចំការកៅស៊ូ ។

-២មេសា : សម្តេចសីហនុ លាលែងពីតំណែងប្រមុខរដ្ឋ ខៀវ សំផន ឡើងកាន់ជាតំណែងប្រមុខរដ្ឋ (ប្រធានប្រេស៊ីឌីយ៉ូម នៃរដ្ឋកម្ពុជាប្រជាធិតេយ្យ) សម្តេចសីហនុ នៅជាប់ព្រះអង្គជាអ្នកទោស ក្នុងវាំងនាប្រាសាទខេមរិន្ទ ព្រះញាតិវង្សជាច្រើនបានបាត់ខ្លួន ។

-៤មេសា : ជនភៀសខ្លួនខ្មែរនៅបារាំងបានសរសេរពាក្យបណ្តឹងទៅអង្គការសហប្រជាជាតិ ទៅ យូណេស្កូ ទៅអង្គការសិទ្ធិមនុស្ស ទៅអង្គការលើកលែងទោសអន្តរជាតិ សម្តែងពីភាពឃោរឃៅនៃរបបកម្ពុជា ប្រជាធិបតេយ្យលើពលរដ្ឋខ្លួនឯង តែពុំមានចម្លើយតបណាមួយមកវិញទេ ។

-៦មេសា : ប៉ែន នុត ដាក់ពាក្យលាលែងពីតំណែងនាយករដ្ឋមន្ត្រីគេចខ្លួនរួចមកដល់ប្រទេសបារាំង ។

-១១-១៣ មេសា : ប្រជុំវិសាមញ្ញដំបូង និងតែមួយនៃ "សភាតំណាងប្រជាពលរដ្ឋកម្ពុជា" ក្រោមអធិបតីភាពនៃ នួន ជា មានលំដាប់ថ្នាក់ទី៣នៃអង្គការនៅពេលប្រជុំនោះ សាឡុតស បានសម្រេចបង្ហាញខ្លួនថា ឈ្មោះ ប៉ុល ពត ។

ឆ្នាំ ១៩៧៦

១៤ មេសា : រដ្ឋាភិបាលថ្មីដឹកនាំដោយ ប៉ុល ពត

- នាយករដ្ឋមន្ត្រី : ប៉ុល ពត
- ឧបនាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីការបរទេស : អៀង សារី
- ឧបនាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីសេដ្ឋកិច្ច :វ៉ន វេត
- ឧបនាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រីការពារជាតិ : សុន សេន
- រដ្ឋមន្ត្រីអមទីស្តីការគណៈរដ្ឋមន្ត្រី : គាត ឆុន
- រដ្ឋមន្ត្រីព័ត៌មាន និងឃោសនា : ហ៊ូ នឹម

(តទៅលេខក្រោយ)



ពុទ្ធប្បវត្តិអមដោយរូបភាព

A Pictorrial Biography of Saky amuni Buddha



- ❖ រូបភាព និងរឿងដើមជាភាសាថៃ ដោយ គុណាប៉ាយុតា
- ❖ បកប្រែជាភាសាអង់គ្លេស ដោយ ហ្សីត .អេ.លី
- ❖ ផាត់ពណ៌ដោយ យ៉ាន់ ហ្វាលី
- ❖ បកប្រែជាភាសាខ្មែរដោយភិក្ខុ គង់ អាំ

- ❖ Original Illuatration and Naration in Thai by Gunapayuta.
- ❖ Translation into English by A Lu.
- ❖ Coloring by Yann Fang Lee
- ❖ Translation into Khmer by Bhikkhu Kong Am.

៦១- អ្វីៗសព្វយ៉ាងបានរៀបចំរួចជាស្រេច ព្រះសិទ្ធត្ថគង់ក្នុងរាជរថដ៏ល្អវិចិត្រអស្ចារ្យរចនាដោយក្បូនក្បាច់ផ្សេងៗ យាងចេញពីព្រះបរមរាជវាំង ទ្រង់បានទស្សនាជុំវិញរាជធានី ។ គ្រប់ទីកន្លែងទាំងអស់ ដែលព្រះអង្គយាងដល់ ទ្រង់បានទតឃើញហ្វូងមហាជនទាំងឡាយមានទឹកមុខញញឹមស្រស់ស្រាយរាកទាក់ អបរសាទរ ទទួលស្វាគមន៍ព្រះអង្គគ្រប់ៗគ្នា ។ នៅពេលឃើញព្រះអង្គភ្លាម អ្នកខ្លះស្រែកសាទរ ថ្វាយពរជ័យថា "សូមព្រះរាជបុត្រជាម្ចាស់មានព្រះជន្មយឺនយូរ!" អ្នកខ្លះទៀតចូលទៅជិតរាជរថ ហើយក៏បានបាចផ្កាគន្ធពិដោរនៅលើផ្លូវ ។ ចំណែករាជរថចេះតែបន្តដំណើរសន្សឹមៗតាមបណ្តោយដងផ្លូវដែលក្រាលគ្របទៅដោយផ្កាភ្ញី ។

៦២- ពេលនេះស្រាប់តែមានមនុស្សចាស់ម្នាក់សក់ស្កូវព្រោងសម្លៀកបំពាក់គគ្រិចដាច់រយីរយៃ ដើរខ្ញើចៗ ញ័រញាក់ទទ្រាក់ទទ្រើកចេញពីផ្ទះគាត់មកដល់ថ្នល់ ហើយគ្មាននរណាម្នាក់ឃើញគាត់ជាមុន និងបានឃាត់គាត់ឡើយ ។ មុខគាត់ស្គាំងស្គមខូងផតឡើយខ្មៅជាដុំៗ គួរឱ្យអណោចអធ័ម ស្បែកស្វិតជ្រីវជ្រួញរយីករយាក ភ្នែកទាំងទ្វេងងឹតងងល់អន្ធការ ឯទន្តាសោតសល់តែមួយក្នុងមាត់ក្រពិតៗ ស្វិតក្រៀមក្រោះ ។ ខ្នងគាត់កោងគមដំណើរទ្រេតទ្រោតយ៉ាងខ្លាំង ដៃកាន់ឈើច្រកទប់កាយស្រែកទ្រហោយំសុំទានតាមផ្លូវ គាត់ប្រាកដជាដាច់ពោះស្លាប់មិនខានបើសុំទានគេមិនបានធឹទេនោះ ។ (តទៅលេខក្រោយ)

61- Everything was ready. Prince Siddhartha, in a splendid carriage, came out of the palace and toured around the city. Everywhere he saw crowds of people with smiling faces enthusiastically welcoming him. On seeing the prince, some people shouted: "Long lives the prince!", while others approached his carriage and spread flowers on the road. The carriage thus continued moving on along the flower-covered path.



62- All at once, a white-haired old man, clad in dirty rags and tatters, limped out of his house and reached the road before anyone could stop him. His haggard face was full of wrinkles and freckles, his eyes dull and dim, and only one tooth remained in his dry and withered mouth. His back was severely hunched and he had to rely on a cane to move his body. Wailing and begging along the road, he would certainly have starved to death if he had failed to get food for even one day. *(Continued Issue After)*

តមកទំព័រទី ០៤

មហាឧត្តមសេនីយ៍ណាបន្ត...

សេចក្តីសន្និដ្ឋាន :ប្រវត្តិសាស្ត្រខ្មែរ ដែលបានថែងទុកក្តី ការតាមដានពិនិត្យនូវព្រឹត្តិការណ៍ពាក់ព័ន្ធ និងមហិច្ឆិតាលោភលន់របស់យួន និងសៀមក្តី ការចងចាំ និងការកត់ត្រាទុកនូវហេតុការណ៍ផ្សេងៗ ក្នុងរឿងជនជាតិខ្មែរ និងជនជាតិយួន ជាតិសៀមក្តី ទាំងអស់នេះសុទ្ធតែមានអត្ថប្រយោជន៍ អត្ថន័យខ្លឹមសារសំខាន់ណាស់ ដើម្បីរឭកដាស់តឿន សតិស្មារតីកុលបុត្រ កុលធីតាខ្មែរ និងមហាជនជាតិខ្មែរទាំងអស់ឱ្យបានចេះគិតពិចារណា និងបណ្តុះបណ្តាលទឹកចិត្ត គោលជំហរឧត្តមគតិ មនសិការស្នេហាជាតិ មាតុភូមិ ជួយការពារទ្រទ្រង់ ថែរក្សាទឹកដីរបស់ខ្មែរ ឱ្យមានអត្តសញ្ញាណជាប្រទេស និងជាប្រជាជាតិខ្មែរពិតប្រាកដ ។ ជាពិសេស ឱ្យបានជាប្រទេសជាប្រជាជាតិមានឯករាជ្យពេញបរិបូរ មានសិទ្ធិសេរីភាព មានអំណាចពេញបរិបូរ ហើយពិតប្រាកដឱ្យបានដូចជាអារ្យប្រទេសនានានៅក្នុងលោកនេះ ។

គោលបំណងនៃការលើកយកប្រវត្តិសាស្ត្រខ្មែរត្រង់វគ្គឧត្តមសេនីយ៍ ទ្រឿងមិញយ៉ាង ដែលជាសេនាភ្នែកច្រមុះរបស់ស្តេចយួន មិញម៉ាង មកធ្វើការប្រៀបធៀបជាមួយមហាឧត្តមសេនីយ៍ ហ៊ុង សែង នេះដើម្បីឱ្យជនជាតិខ្មែរ ពិនិត្យគិតពិចារណាថា : បើប្រវត្តិ-សាស្ត្រខ្មែរ បានប្រាប់ពីបេសកកម្មឧត្តមសេនីយ៍ ទ្រឿងមិញយ៉ាង ឱ្យបានដឹងច្បាស់ហើយថា ស្តេចយួនក្តី មេដឹកនាំយួនក្រោយៗមកក្តី សុទ្ធតែមានគម្រោងផែនការទុករួចជាស្រេចអស់ទៅហើយ តាំងពីពេលមានមហាឧត្តមសេនីយ៍ ហ៊ុង សែង ទៅទៀត ចុះមកពីហេតុអ្វីបានជាមកដល់សម័យឆ្នាំ ១៩៧៩ នេះ មានលេចហេតុការណ៍ចេញ មកដូចគ្នាបេះបិតកាលពីសម័យឆ្នាំ១៨៣៤ នោះដែរដូច្នេះ ?

ការបង្ហាញរូបភាពដូចគ្នាបេះបិតដូច្នេះ មិនខុសគ្នាពីលទ្ធផលនៃការធ្វើចំណោទក្នុងលេខគណិត ជាលេខបូកក្តី ជាគុណក្តី សងក្តី ចែកក្តី គឺសុទ្ធតែចេញលទ្ធផលពិតប្រាកដត្រឹមត្រូវទាំងអស់ ទើបហៅថាពិតប្រាកដមែន ។

គេពុំដែលឃើញ ១០០ បូកនឹង ១០០ ចេញ ៣០០ នោះថាត្រឹមត្រូវពិតប្រាកដនោះទេ ។

រឿងយួនយៀកណាម និងខ្មែរកម្ពុជា ក៏ដូចគ្នាដែរ បើឧត្តមសេនីយ៍ ទ្រឿងមិញយ៉ាង បានផ្ញើចុតហ្មាយទៅស្តេចយួនថា "សូមទទួលកំហុស ដោយបានធ្វើឱ្យបាត់បង់សម្បត្តិមួយ ដែលជារបស់ព្រះអង្គពិតៗ ! " រួចហើយលេបថ្នាំសម្លាប់ខ្លួនឯងទៅ តើមកពីហេតុអ្វី?

លុះមកដល់សម័យឧត្តមសេនីយ៍ ហ៊ុង សែង បើកាលណាត្រូវធ្វើឱ្យបានគង់វង្សសម្បត្តិមួយជារបស់ព្រះអង្គស្តេច មិញជីហ្វូ ពិតប្រាកដមែននោះ តើមហាឧត្តមសេនីយ៍ ហ៊ុង សែង ជាអ្នកណាពិតប្រាកដ?

តើប្រវត្តិសាស្ត្រខ្មែរ នៅក្នុងសម័យកាលមហាឧត្តមសេនីយ៍ ហ៊ុង សែង នេះថែងចារិកទុកថាដូចម្តេច ?

តើមហាឧត្តមសេនីយ៍ ហ៊ុង សែង និងឧត្តមសេនីយ៍ ទ្រឿងមិញយ៉ាង មានលក្ខណៈដូចគ្នាបេះ បិតពិតមែនឬទេ ? ៕

តមកទំព័រទី ០១

មានអ្វីប្លែកនៅហ្វីឡាដែលហ្វៀ...

II. នៅហ្វីឡាដែលហ្វៀ "កាសា" ធ្វើពិធីជប់លៀង :

ពិធីជប់លៀងមួយ បានត្រូវប្រារព្ធឡើងដោយគណៈ-កម្មការនាយកក្នុងនាម "កាសា" (សហគមព្រឹទ្ធាចារ្យខ្មែរ-អាមេរិកាំង) នៅថ្ងៃទី១២ ខែមិនា នាភោជនីយដ្ឋានខ្មែរថ្មីមួយឈ្មោះ "ការី" ដើម្បីបង្ហាញពីការជួបជុំសមាជិកសហគមន៏ខ្មែរ នៅហ្វីឡាដែលហ្វៀនេះ ។



ពិធីជប់លៀងនេះ ស្ថិតនៅក្រោមការដឹកនាំរបស់ប្រធានស្តីទី ជិន វុត្ថា ហើយមានការចូលរួមដោយភ្ញៀវប្រមាណ ១៥០នាក់ មកពីគ្រប់និន្នាការ ។ លោក ស៊ូវិន ជូ ជាប្រធានសមាគមបានលាលែងពីតំណែងដោយមានជម្ងឺ ហើយសមាគម "កាសា" នេះបានធ្វើពិធីជប់លៀងនៅក្នុងស្ថានភាពចម្រូងចម្រាសនៅឡើយ - សូមអានសេចក្តីរាយការណ៍ អ៊ុម លឿម នៅទំព័រទី៣ ។

III. មូលនិធិសិក្សាធិការខ្មែរ :

នារាត្រីថ្ងៃទី១២ មិនា នោះដែរ រាត្រីសមោសរមួយទៀត បានប្រព្រឹត្តទៅនៅហ្វីឡាដែលហ្វៀ ជាមួយនឹងភ្ញៀវប្រមាណ ១៥០នាក់ នៅភោជនីយដ្ឋាន "សាយកន ម៉ាក់ស៊ុម" រៀបចំឡើងដោយមូលនិធិសិក្សាធិការខ្មែរ ដើម្បីស្វែងរកថវិកាទៅជួយនិស្សិតក្រីក្រ ដែលរៀនពូកែឱ្យអាចបន្តការសិក្សាទៅមហា-វិទ្យាល័យទៀតបាន ។

នារាត្រីនោះ លោកវេជ្ជបណ្ឌិត ខៅ សំរ៉ង ជាប្រធានមូលនិធិ បានប្រកាសពីសកម្មភាពបីឆ្នាំមកហើយ ក្នុងការជួយដល់ការសិក្សារបស់និស្សិតប្រមាណ ៣០០នាក់ និងបង្កើតថ្នាក់រៀនកុំព្យូទ័រមួយទៀតផង ។

រាត្រីនោះ សប្បុរសជននៅហ្វីឡាដែលហ្វៀ. នៅវៀស៊ីនា. នៅនូយ៉ក... រៃប្រាក់បាន ៤០០០ ដុល្លារ សម្រាប់យកទៅជួយដល់យុវជន និងយុវនារីខ្មែរ នៅឯប្រទេសកម្ពុជា ៕

IV. ស្ថានកុងស៊ុលខ្មែរ នៅហ្វីឡាដែលហ្វៀ

ព័ត៌មានក្រៅផ្លូវការនៅឡើយមួយ បានឱ្យដឹងថា រដ្ឋាភិបាលខ្មែរ បានសម្រេចបង្កើតស្ថានកុងស៊ុលខ្មែរមួយ នៅទីក្រុងហ្វីឡាដែលហ្វៀ ដែលអាចនឹងដំណើរការបាននៅខែកញ្ញាខាងមុខ ។

នេះជាទីក្រុងទី៣ បន្ទាប់ពីឡុងប៊ិច និងទីក្រុងឡូវែល ដែលហ្វីឡាដែលហ្វៀ បានទទួលកិត្តិយសក្នុងការបង្កើនទំនាក់ទំនងជាមួយកម្ពុជា ក្នុងកិរិតខ្ពស់មួយទៀត ។ យើងនឹងជូនដំណឹងបន្តទៅទៀតនៅពេលមានការវិវឌ្ឍន៍ថ្មីៗទៀត ៕

ហោរាសាស្ត្រប្រចាំថ្ងៃទី២៦ មិនា_០៨ មេសា ២០១០

ឆ្នាំជូត : (ពន្សទេព្តាប្រុស ធាតុទឹក)

រាសីលោកអ្នកល្អជាមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនល្អគួរលាស់ទៅមុខដោយសន្សឹម។ ។ ក្នុងរយៈពេលនេះ ពិតមែនតែបានជួបនិងឱកាសល្អខ្លះៗក្តី ក៏លោកអ្នកមិនត្រូវធ្វើឲ្យមានការធ្វេសប្រហែសដែរ ព្រោះវាអាចនាំឲ្យបាត់បង់ទ្រព្យ ។ ចំពោះគូស្នេហ៍ ក្នុងរយៈពេលនេះមានការយល់អធ្យាស្រ័យគ្នាធម្មតា ៕

ឆ្នាំឆ្លូវ : (ពន្សមនុស្សប្រុស ធាតុដី)

រាសីលោកអ្នកល្អជាមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អគ្រាន់បើ ។ ក្នុងរយៈពេលនេះ ថ្វីត្បិតតែការងាររកស៊ីទៅជួបនឹងឧបសគ្គខ្លះៗក្តីក៏លោកអ្នកអាចបោះជំហានទៅមុខដោយសន្សឹមៗបានដែរ ។ ចំពោះគូស្នេហ៍ក្នុងរយៈពេលនេះគឺអាចគិតគូរៀងអាពាហ៍ពិពាហ៍បាន ៕

ឆ្នាំខាល : (ពន្សយក្សស្រី ធាតុឈើ)

រាសីលោកអ្នកល្អជាមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អគ្រាន់បើ ។ ក្នុងរយៈពេលនេះលោកអ្នកត្រូវប្រយ័ត្នប្រយែងក្រែងមានបងប្អូនញាតិមិត្តនាំរឿងក្តៅក្រហាយមកឲ្យអាចនាំឲ្យមានអំពល់ទុក្ខដាក់ខ្លួនព្រមទាំងអាចបង់ខាតទ្រព្យច្រើនទៀតផង ។ ចំពោះគូស្នេហ៍ ក្នុងរយៈពេលនេះមានភាពស្និទ្ធស្នាលដូចធម្មតា ៕

ឆ្នាំថោះ : (ពន្សមនុស្សស្រី ធាតុឈើ)

រាសីលោកអ្នកឡើងខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនល្អគួរលាស់ទៅមុខជាលំដាប់ ។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកបានប្រកបការងារអ្វីក៏ដោយ ក៏អាចទទួលបានផលសម្រេចសមតាមការបំណងប្រាថ្នាទាំងអស់ ។ ចំពោះគូស្នេហ៍ ក្នុងរយៈពេលនេះ ប្រកបដោយសេចក្តីសុខក្សេមក្សាន្ត ៕

ឆ្នាំរោង : (ពន្សទេព្តាប្រុស ធាតុមាស)

រាសីលោកអ្នកឡើងខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អណាស់ ។ ក្នុងរយៈពេលនេះលោកអ្នកមានអារម្មណ៍ភ្លឺថ្លា គំនិត ប្រាជ្ញាឈ្លាសវៃ ទោះបានប្រកបការងារអ្វីក៏អាចទទួលបានផលសម្រេចតាមការបំណងប្រាថ្នាទាំងអស់ ។ ចំពោះគូស្នេហ៍មានភាពល្អកល្អីនល្អណាស់ ៕

ឆ្នាំម្សាញ់ : (ពន្សមនុស្សប្រុស ធាតុភ្លើង)

រាសីលោកអ្នកល្អជាមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរបានកាក់កបល្អគ្រាន់បើ ។ ក្នុងរយៈពេលនេះ មុជមិនជ្រៅទៅមិនឆ្ងាយ តែបើលោកអ្នករកស៊ីនាយអាយនៅក្បែរៗ គឺអាចរកផលចំណូលហូរចូលច្រើនគ្រាន់បើ ។ ចំពោះគូស្នេហ៍ ក្នុងរយៈពេលនេះ មិនសូវយល់ចិត្តថ្លើមគ្នាទេ ៕

ឆ្នាំមមី : (ពន្សទេព្តាស្រី ធាតុភ្លើង)

រាសីលោកអ្នកល្អជាមធ្យម ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនល្អគួរលាស់ទៅមុខដោយសន្សឹម។ ។ ក្នុងរយៈពេលនេះ ដោយទំនាយទាយថាអាចបង់ខាតទ្រព្យខ្លះៗនោះ ដូច្នេះចូរកុំឲ្យគេខ្ចីរបស់របរមានតម្លៃឡើយ ។ ចំពោះគូស្វាមីភរិយា ក្នុងរយៈពេលនេះ មានផលប៉ះទង្គិចគ្នាខ្លះ ៕

ឆ្នាំមមែ : (ពន្សទេព្តាស្រី ធាតុមាស)

រាសីលោកអ្នកឡើងខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនល្អគួរលាស់ទៅមុខជាលំដាប់ ។ ក្នុងរយៈពេលនេះ លោកអ្នកជាមនុស្សពូកែខាងសម្តីវោហារ ទោះជាបាននិយាយស្តីច្រើនបន្តិចក្តី ក៏មិនឥតប្រយោជន៍ដែរ ។ ចំពោះគូស្នេហ៍ ក្នុងរយៈពេលនេះប្រកបដោយភាពផ្អែមល្ហែមដូចទឹកឃ្មុំ ៕

ឆ្នាំវក : (ពន្សយក្សប្រុស ធាតុដែក)

រាសីលោកអ្នកស្រុតចុះខ្លាំង ។ រាល់កិច្ចការងាររកស៊ីជួញដូរជួបនឹងបញ្ហាស្មុគស្មាញច្រើន ។ ក្នុងរយៈពេលនេះ ថ្វីត្បិតតែលោកអ្នករត់ចុះរត់ឡើងមានការមមាញឹក និងហត់នឿយច្រើនក្តី តែភោគផលកម្រៃហូរចូលបានតិចតួចស្តួចស្តើងប៉ុណ្ណោះ ។ ចំពោះស្នេហា ក្នុងរយៈពេលនេះប្រយ័ត្នមានអ្នកទីពាចូលជ្រៀតជ្រែក ៕

ឆ្នាំរកា : (ពន្សយក្សប្រុស ធាតុដែក)

រាសីលោកអ្នកឡើងខ្ពស់ត្រដែត ។ រាល់កិច្ចការងាររកស៊ីជួញដូរមានការរីកចម្រើនល្អគួរលាស់ទៅមុខជាលំដាប់ ។ ក្នុងរយៈពេលនេះ ទោះជាលោកអ្នកបានជួបនឹងគូប្រជែងដើងខ្លាំងយ៉ាងណាក្តី ក៏មិនបញ្ហាអ្វីដែរ ព្រោះលោកអ្នកយកប្រៀបឈ្នះជាប់ជានិច្ច ចំពោះកម្លោះក្រមុំក្នុងរយៈពេលនេះអាចទាក់ទងគ្នា និងបានក្លាយជាគូស្នេហ៍ដ៏ប្រពៃមួយគូ ៕

ឆ្នាំច : (ពន្សយក្សស្រី ធាតុដី)

រាសីលោកអ្នកស្រុតចុះខ្លាំង ។ រាល់កិច្ចការងាររកស៊ីជួញដូរជួបនិងរឿងរកាំរកូសច្រើន ។ ក្នុងរយៈពេលនេះទោះជាលោកអ្នកបានប្រកបការងារអ្វីក៏ដោយចូររៀបចំគម្រោងផែនការជាមុន ទើបពុំមានការថ្លោះធ្លោយ ។ ចំពោះគូស្នេហ៍ ក្នុងរយៈពេលនេះច្រើនពាក់មុខយក្សដាក់គ្នា ៕

ឆ្នាំកុរ : (ពន្សមនុស្សស្រី ធាតុទឹក)

រាសីលោកអ្នកស្រុតចុះខ្លាំង ។ រាល់កិច្ចការងាររកស៊ីជួញដូរជួបនឹងបញ្ហាលំបាកៗច្រើន ។ ក្នុងរយៈពេលនេះ ចូរកុំធ្វេសប្រហែសឲ្យសោះ ជាពិសេសក្នុងការទូទាត់បញ្ជីប្រាក់កាសផ្សេងៗប្រយ័ត្នមានការភ្លាំងភ្លាត់តែបន្តិចអាចខាតបង់ទ្រព្យច្រើន ដែលមិនអាចគណនាបានឡើយ ។ ចំពោះគូស្វាមីភរិយាប្រយ័ត្នមានគេអុជអាលឲ្យបែកបាក់គ្នា ៕

គួរទទួលទានអាហារបែបណា ទើបរាងស្អាត

•ដើម្បីឈានឆ្ពោះទៅរកភាពស្រស់ស្អាតទាំងនេះបាន អ្នកចាំបាច់ត្រូវអនុវត្តប្រការសំខាន់ៗដូចខាងក្រោមនេះ ៖

១– ល្ពៅលាយជាមួយខ្ទឹមកាត់បន្ថយទម្ងន់ : ចិតយកខ្ទឹមមួយបន្ទះហើយចិញ្ច្រាំឲ្យម៉ដ្តប្រចាប់យកទឹកមកវែងស់ជាមួយទឹកឲ្យបាន១០នាទី ។ បន្ទាប់ពីនេះប្រចាប់សាច់ផ្លែម្នាស់ ហើយល្អងមួយមុខពាក់កណ្តាល(តូចល្មម) ហើយប្រចាប់យកទឹករួមគ្នាមកលាយជាមួយទឹកខ្ទឹមងាស់ ដោយដាក់កម្តៅបន្តិចមុននឹងយកមកទទួលទាន ។ រូបមន្តនេះអាចជួយដុតបំផ្លាញជាតិខ្លាញ់ និងកាត់បន្ថយការស្រេកឃ្លានបន្ថែមបានល្អ ។

២– មិនត្រូវផ្អាកបង្អែមទាំងស្រុងទេ : ជាការពិតណាស់ បង្អែមធ្វើឲ្យកម្រិតជាតិស្ករក្នុងឈាមឡើងខ្ពស់ និងធ្វើឲ្យធាត់ហេវ ប៉ុន្តែទោះបីយ៉ាងណា អ្នកក៏មិនត្រូវបោះបង់វាចោលទាំងស្រុងនោះទេ ព្រោះជាតិស្ករក៏ផ្តល់នូវថាមពល និងភាពស្អាតផុរផង់បានមួយកម្រិតដែរ ។

៣– ទឹកខ្ទឹម : គួរហាន់យកខ្ទឹមមួយបន្ទះមួយមកត្រាំក្នុងទឹកក្តៅឧណ្ហៗ ហើយមកទទួលទានឲ្យបានញឹកញាប់ ព្រោះទឹកខ្ទឹមជួយកាត់បន្ថយអាស៊ីដក្នុងក្រពះ ដែលជួយជំរុញការរំលាយអាហារ និងធ្វើឲ្យអាហារផ្អាប់ទុកក្នុងពោះដែលបង្កឲ្យប៉ោកពោះធ្លល់ពោះទៀតផង ។

៤– ក្លិនស្អាប់អាហារ : អាហារប្រភេទខ្លះមានក្លិនក្រអូបឈ្ងុយឈ្ងប់ធ្វើឲ្យទាក់ទាញចង់ទទួលទានអាហារស្ទើរទ្រាំពុំបាន។ ប្រសិនបើចង់កាត់បន្ថយចំណីអាហារទាំងនេះ អ្នកត្រូវរកទៀនក្រអូបមកអុជ ឬប្រេងក្លិនក្រូចឆ្មារ ក្លិនក្រូចសើច ក្លិនក្រូចមកដាក់ក្នុងបន្ទប់ខ្លះ ជួយទប់ស្កាត់ការស្រេកឃ្លានអាហារ ។

៥– បង្អង់ការទទួលទាន : បើអ្នកធ្លាប់តែទទួលទានមួយថ្ងៃៗឥតទំនេរមាត់ ឥឡូវនេះអាចបញ្ឈប់វាវិញខ្លះបានហើយ ដើម្បីប្តូររូបរាងឲ្យស្អាតខុសប្លែកជាងពីមុនវិញ ។ ត្រូវបោះបង់អាហារខ្លះដែលអ្នកចូលចិត្ត ហើយយកពេលនេះ មកបំពេញកិច្ចការងារផ្សេងៗជំនួសវិញ ៕

មូលនិធិសិក្សាធិការខ្មែរ យុវជនចាប់អារម្មណ៍

•••ឡានិកា បានចូលរួមរាត្រីប្រមូលកំរៃរបស់មូលនិធិសិក្សាធិការខ្មែរ នារាត្រីដ៏រីករាយមួយ ដែលមានចាស់លាយក្មេង មានវប្បធម៌ខ្មែរ និងបរទេស មានភ្លេងប្រជាប្រិយ និងសម័យ តើយុវនារី ឡានិកា គិតពីអ្វីខ្លះ? យុវនារីខ្មែរ ទៅរៀនសាលាអាមេរិកាំង ធំធាត់និយាយ និងយល់អង់គ្លេសស្ទាត់ជំនាញ តែនៅតែខំរៀន និងយល់វប្បធម៌ខ្លួនដ៏ជំនាញដូចគ្នា សូមតាមដានការគិតរបស់ ឡានិកា អង់ប៉ាក់ ជាភាសាអង់គ្លេស :

On Saturday, March 13, 2010 the Cambodian Education Excellence (CEE) Foundation had their annual benefit. The event took place at Saigon Maxim, a local Philadelphia restaurant on 6th and Washington Streets. The night consisted of speeches from those working closely with the students in Cambodia, a live Cambodian band, dancing, raffles, and food. Many people came out to support CEE Foundation.

The CEE Foundation help underprivileged children in Cambodia reach higher goals. Most recently, 31 brand new computers were purchased for the children. The foundation provides scholarships for students who show great academic performances at school. Donations from throughout the night will be put towards the foundation's goals of educating more of Cambodia's youth. The foundation's mission is to promote and encourage Cambodian students of the present and future to pursue education to enrich their lives.

Those that attended the event where wowed with the live band. Throughout the night people filled the dance floor. Some even participated in singing a song as they danced. Many danced the night away, whether or not they knew how to do Khmer social dance moves. It was a light-hearted and rich atmosphere.

Raffle tickets were sold by adopted Cambodian children and their "big sisters," or high school girls who take on the role of an older sibling for the girls. The event brought two different Cambodian communities together: the American community whom adopted Khmer culture as their own, and the Khmer community whom adopted the American culture as their own. Seeing the harmony between the two groups of people brought a feeling of unity to the event.

It was good to see many people attend, and especially to see younger Cambodian students from the Philadelphia area. It is important to be able to bridge gaps between the different parts of the Cambodian community, and most importantly to continue to support not only ourselves but those of our homeland. Education is important everywhere and to everyone, whether it be in the United States or Cambodia, American or Cambodian.

Readers can learn more or donate at: CEEFoundation.org

(តមកពីទំព័រទី ០៦) ខ្មែរងើប...

ខ្មែរ គឺយើងជាខ្មែរដូចៗគ្នាទេ ជាពិសេស បងប្អូនខ្មែរគ្រប់គណបក្សទាំងអស់ រួមទាំងគណបក្សប្រជាជនផងដែរ សូមឱ្យបានមករួបរួមគ្នាវេញធ្លុងជាមួយគ្នា ងើបឡើងប្រឆាំងតស៊ូយ៉ាងណា ដើម្បីវាស្នាអនាគតពូជពង្សខ្មែរយើង ការពារយ៉ាងណាកុំឱ្យដាច់ផុតពូជខ្មែរមហានគរដ៏រុងរឿងនៃដូនតាយើងតាំងពីព្រេងនាយមក ។

ទន្ទឹមគ្នានេះដែរ បើយើងជាខ្មែរម្នាក់ៗ មិនប្រឹងងើបទេ តើឱ្យបរទេសណាគេងើបជំនួសយើង? ពាក្យស្លោកបរមបុរាណបានថែងថា "ស៊ូស្លាប់ខ្លួន កុំឱ្យស្លាប់ជាតិ" ដូច្នេះ ដែលយើងមិនព្រមងើបនោះ សុខចិត្តឱ្យស្លាប់ជាតិឬ? ឬមួយបងប្អូនយល់ថា វត្តមានយួនក្លាយខ្លួនជាខ្មែរ រស់នៅជំនួសខ្មែរ ដែលមានសារជាតិជាខ្មែរ ពិតប្រាកដជាការល្អប្រពៃហើយទេដឹង? ម្យ៉ាងវិញទៀត បើយើងងើបទាំងអស់គ្នា ហើយមានវាសនាអាចបំរើប្រជាជាតិបានជោគជ័យនោះ ក៏ពុំមែនជាជ័យសម្រាប់តែគណបក្សសិទ្ធិមនុស្សទេ ពោលគឺជាមហាជ័យជំនះ សម្រាប់ខ្មែរគ្រប់ៗរូបឈ្នះទាំងអស់គ្នា ជាពិសេស គឺឱ្យតែមានឈ្មោះជាខ្មែរ គឺយើងមានជោគជ័យដូចៗគ្នាទាំងអស់ ព្រោះគណបក្សសិទ្ធិមនុស្សអត់មានរើសអើង ប្រកាន់បក្សពួក ឬគំនួន ចាត់ទុកខ្មែរណាថា ជាសត្រូវស្លាប់រស់ឡើយ គឺរាប់ជាមហាមិត្ត ជាបងជាប្អូន ជាខ្មែររួមលោហិតតែមួយ រួមឈាមជ័រជាខ្មែរ មានមនសិការជាខ្មែរ ពិតប្រាកដដូចៗគ្នា ហើយយើងនឹងខិតខំរួមដៃគ្នា ស្តារឡើងវិញនូវពូជអម្បូរខ្មែរអង្គរឡើងវិញទាំងអស់គ្នា ដើម្បីព្រលឹងជាតិ មាតុភូមិ ដែលធ្លាប់ល្បីរុងរឿង មានកិត្តិនាមសុសសាយយ៉ាងឧដ្ដុង្គឧត្តមតាំងពីបុរាណសម័យមក ពោលគឺខ្មែរអច្ឆរិយៈ ខ្មែរអមតៈ ។ល។

ក្នុងអត្ថន័យដូចបានរៀបរាប់ខាងលើនេះ នោះគ្រាន់តែជាការជួយរំលឹកឡើងវិញថែមតែប៉ុណ្ណោះ ចំពោះការអំពាវនាវ ហើយអំពាវនាវទៀតរបស់លោក កឹម សុខា ប្រធានគណបក្សសិទ្ធិមនុស្ស ឱ្យខ្មែរយើងគ្រប់ៗរូប គ្រប់គណបក្សឱ្យបានមករួបរួមគ្នាឡើងវិញ ឈ្លលនទៀលយ៉ាងណាឱ្យបានជាដាច់ខាតឱ្យបានចុះឈ្មោះបោះឆ្នោតដោយត្រឹមត្រូវ សុចរិត យុត្តិធម៌តាមមាគ៌ាប្រជាធិបតេយ្យពិតប្រាកដ ឥតល្អៀងនា អនាគតក្នុងឆ្នាំ ២០១២ និង ២០១៣ ខាងមុខនេះប៉ុណ្ណោះ ៕

តមកទំព័រទី ០៣ ត្បូរអានពីជំរឿនកុំឱ្យ...

ឱ្យទៅរកចម្លើយពីផ្ទះនិមួយៗ ។

ដូច្នេះ ច្បាប់ក៏អាចពិន័យយើងវិញដែរ គឺ ១០០ ដុល្លារ បើយើងឆ្លើយសំនួរមិនអស់នៅចម្លោះ ឬក៏ពិន័យ ៥០០ដុល្លារ បើយើងឆ្លើយខុសការពិត ។

ដូច្នេះ គឺជាសារៈសំខាន់ណាស់ ដែលត្រូវបំពេញលិខិត Census នោះ ហើយផ្ញើមកឱ្យការិយាល័យ Census វិញ ។ រដ្ឋធម្មនុញ្ញបានបង្កើតជំរឿនប្រជាជន ហើយរាប់ឱ្យបានត្រឹមត្រូវ ដើម្បីបែងចែងតំណាងឱ្យបានយុត្តិធម៌ បែងចែកចំនួនអាសនៈនៅសភាជាតិឱ្យបានស្មើភាពគ្នា ។

លោកអ្នកដឹងទេថា ថវិកា ៤០០ពាន់លានដុល្លារ (ប៊ីលីយ៉ុង) បានត្រូវចែកជារៀងរាល់ឆ្នាំដល់រដ្ឋចំនួន ៥០ ដូច្នេះ លោកអ្នកចង់ឃើញតំបន់យើងទទួលផលស្មើភាពគ្នាដែរ ដើម្បីយកមកសង់សាលារៀន, ធ្វើផ្លូវ, ធ្វើមន្ទីរពេទ្យ, ធ្វើរថយន្តដំណើរក្នុងក្រុង ឬធ្វើសេវាសង្គមកិច្ចដល់ខ្លួនយើង ! ។

ឥឡូវនេះក្រសួងជំរឿនប្រជាជននេះ ត្រូវការមនុស្សធ្វើការរាប់ពាន់នាក់ ដូច្នេះ សូមទូរស័ព្ទភ្លាមទៅលេខ ៨៦៦-៨៦១ ២០១០ ដើម្បីទទួលបានការងារធ្វើនៅហ្វីឡាដែលហ្វៀ ឬនៅក្បែរៗនេះ អ្នកដាក់ពាក្យរាប់ពាន់នាក់នឹងត្រូវធ្វើតេស ហើយអញ្ជើញឱ្យ ទៅធ្វើការនៅប៉ុន្មានសប្តាហ៍ខាងមុខនេះ ភ្នាក់ងារកត់ត្រានឹងបំពេញលិខិតបាន ១៧.៧៥ ដុល្លារក្នុងមួយម៉ោង និងភ្នាក់ងារថ្នាក់ដឹកនាំបាន ១៩.២៥ ក្នុងមួយម៉ោង ។

ដូច្នេះសូមលោកអ្នកបំពេញលិខិត Census ហើយផ្ញើមកវិញឱ្យបានមុនថ្ងៃទី១ ខែមេសា ឆ្នាំ២០១០ ។ ក្រសួងមានជូនកំណត់ណែនាំ ដើម្បីជួយពន្យល់ក្នុងការបំពេញ ១០សំនួននៃលិខិតជំរឿននោះ ហើយនៅទំព័រក្នុងនៃកាសែតខ្មែរប៉ុស្តិ៍ យើងមានកំណត់ណែនាំជាភាសាខ្មែរសំរាប់ជួយពន្យល់បងប្អូនខ្មែរឱ្យងាយស្រួលក្នុងការបំពេញបាន ៕

-ខ្មែរប៉ុស្តិ៍-

សំនួរសម្រាប់ឆ្លើយមានរង្វាន់

សួរ ១- ទឹកស្ទឹង ឬទន្លេទាំងអស់នៅកម្ពុជា ហូរមិនដែលត្រឡប់ តើពិត ឬមិនពិត?

ឆ្លើយ : មិនពិតទេ សម្រាប់ទន្លេសាប ។

សួរ ២- ហេតុអ្វី ? **ឆ្លើយ** : នៅរដូវវស្សាទឹកហូរពីទន្លេមេគង្គចូលទៅបឹងទន្លេសាប តែដល់រដូវប្រាំងទឹកហូរចេញពីបឹងទន្លេសាបទៅទន្លេមេគង្គវិញ តាមទន្លេមេគង្គ - សរុបសេចក្តី ទន្លេសាបហូរហើយត្រឡប់មកវិញ - នៅពេលនោះ គេនាំគ្នាប្រារព្ធពិធីបុណ្យអុំទូក ។

-អ្នកឆ្លើយត្រូវមុនគេ : **វ៉ាឌី លីម** នៅផ្លូវ Middletown Rhode Iland រង្វាន់គឺ "ភោជនីយដ្ឋាន កាវី" លៀងភោជនាហារ កំដរដោយតន្ត្រីសម័យ នារាត្រីថ្ងៃសៅរ៍ សម្រាប់ជ័យលាភីពីររូប ។

សំនួរថ្មី ត្រូវឆ្លើយឱ្យបានមុនថ្ងៃទី

ដោយៈម៉ម យីន **១៩ ខែមេសា ឆ្នាំ២០១០**

សំនួរ **១- តើទន្លេមេគង្គមានប្រវែងសរុបទាំងអស់ប៉ុន្មានគីឡូម៉ែត្រ?**

២- ចាប់ផ្តើមហូតចេញពីណា ?

៣- ឆ្លងកាត់ប្រទេសណាខ្លះ ?

សូមរសេរចម្លើយមក ខ្មែរប៉ុស្តិ៍ ៤៣៨ Lindley Ave, Philadelphia. PA 19120 ឬ KHMERPOSTUSA@GMAIL.COM

Kavei

ភោជនីយដ្ឋានខ្មែរ

320 OREGON AVENUE . PHILADELPHIA PA 19148 . 215-952-6688



នំបញ្ចុកសម្លខ្មែរ